# ការណែនាំរហ័សអំពីច្បាប់ឱកាសស្មើគ្នានៅរដ្ឋអូស្ត្រាលីខាងត្បូង។

Government of South Australia

Equal Opportunity SA

*ច្បាប់ឱកាសស្មើគ្នារបស់រដ្ឋអូស្ត្រាលីខាងត្បូងការពារអ្នកប្រឆាំងនឹងការរើសអើង ការបៀតបៀនយាយីផ្លូវភេទ និងការធ្វើឱ្យរងគ្រោះ។*

*ការណែនាំនេះនឹងជួយអ្នកឱ្យយល់ដឹងអំពីសិទ្ធិនានារបស់អ្នក និងរបៀបអនុវត្តវា។*

## តើការរើសអើងគឺជាអ្វី?

ការរើសអើងមានន័យថា ការប្រព្រឹត្តចំពោះនរណាម្នាក់ដោយអយុត្តិធម៌ ពីព្រោះតែ៖

- អាយុ។
- ពិការភាព។
- បទពិសោធន៍នៃការរំលោភបំពានពីដៃគូស្និទ្ធស្នាល ឬពីគ្រួសារ។
- ការមានផ្ទៃពោះ ការថែទាំ និងទំនួលខុសត្រូវនានាក្នុងគ្រួសារ។
- ពូជសាសន៍។
- អាការៈខាងក្រៅ ឬមានសម្លៀកបំពាក់តាមបែបសាសនា។
- ស្ថានភាពទំនាក់ទំនង ឬអត្តសញ្ញាណរបស់ដៃគូ។
- ភេទ ស្ថានភាពអន្តរភេទ និងអត្តសញ្ញាណយេនឌ័រ។
- ចំណង់ផ្លូវភេទ។

ការរើសអើងអាចដោយផ្ទាល់ ដូចជាការបដិសេធសេវាកម្ម ឬដោយប្រយោល ដែលបុគ្គលម្នាក់មិនអាចបំពេញតម្រូវការដូចគ្នានឹងអ្នកដទៃ។

## តើការបៀតបៀនយាយីផ្លូវភេទគឺជាអ្វី?

ការបៀតបៀនយាយីផ្លូវភេទ គឺជាការប្រព្រឹត្តិមិនគប្បីណាមួយនៃលក្ខណៈភេទ ដែលវាសមហេតុផលក្នុងការរំពឹងទុកថាបុគ្គលឯទៀតនឹងមានការអាក់អន់ចិត្ត ខ្លាច ឬអាម៉ាស់។ ការបៀតបៀនយាយីផ្លូវភេទត្រូវបានកំណត់តាមទស្សនៈរបស់បុគ្គលដែលមានអារម្មណ៍ថាត្រូវបានគេបៀតបៀនយាយី។ បុគ្គលម្នាក់អាចត្រូវបានបៀតបៀនយាយីផ្លូវភេទដោយនរណាម្នាក់ដែលមានភេទដូចគ្នា ឬភេទផ្សេងគ្នា។

## តើការធ្វើឱ្យរងគ្រោះគឺអ្វីជាអ្វី?

ការធ្វើឱ្យរងគ្រោះមានន័យថាការប្រព្រឹត្តចំពោះនរណាម្នាក់ដោយអយុត្តិធម៌ ពីព្រោះតែពួកគេបានប្រើប្រាស់ច្បាប់ឱកាសស្មើគ្នា ដូចជាការតវ៉ាទៅកាន់ Equal Opportunity SA (គណៈកម្មការឱកាសស្មើគ្នារដ្ឋអូស្ត្រាលីខាងត្បូង) ជាដើម។

## តើការរើសអើង ការបៀតបៀនយាយីផ្លូវភេទ និងការធ្វើឱ្យរងគ្រោះអាចកើតឡើងនៅឯណា?

ច្បាប់ឱកាសស្មើគ្នា ឆ្នាំ 1984 (SA) ផ្តល់ការការពារនៅក្នុងផ្នែកនានានៃជីវិតសាធារណៈ ដូចជា៖

- ពេលអ្នកនៅកន្លែងធ្វើការ ឬដាក់ពាក្យសុំការងារ។
- ក្នុងការស្វែងរកទំនិញ និងសេវាកម្ម។
- នៅពេលស្វែងរកកន្លែងរស់នៅ។
- នៅកន្លែងអប់រំ។
- នៅក្នុងក្លឹបសហគមន៍ និងសមាគមនានា។

## តើអ្នកមានសិទ្ធិអ្វីខ្លះ?

ប្រសិនបើអ្នកជួបប្រទះនឹងការរើសអើង ការបៀតបៀនយាយីផ្លូវភេទ ឬការធ្វើឱ្យរងគ្រោះ អ្នកអាចប្តឹងតវ៉ាទៅ Equal Opportunity SA។

ចូលទៅកាន់គេហទំព័ររបស់ Equal Opportunity SA ឬទាក់ទងមកយើងសម្រាប់ព័ត៌មានអំពីសិទ្ធិនានារបស់អ្នក និងរបៀបធ្វើបណ្តឹងតវ៉ា។

រាល់ការសាកសួរ និងបណ្តឹងតវ៉ាទាំងអស់គឺរក្សាការសម្ងាត់។ យើងនឹងមិនចែករំលែកព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកជាមួយនរណាម្នាក់ឡើយ លុះត្រាតែអ្នកប្រាប់យើងឱ្យធ្វើដូច្នោះ។

## ទាក់ទង Equal Opportunity SA

ទូរសព្ទ៖ (08) 7322 7070

អ្នកហៅទូរសព្ទពីទីជនបទ៖ 1800 188 163

ប្រសិនបើភាសាអង់គ្លេសមិនមែនជាភាសាដែលអ្នកនិយមពេញចិត្តទេ ***សូមទាក់ទងមជ្ឈមណ្ឌលបកប្រែផ្ទាល់មាត់ និងភាសាសរសេរ តាមទូរសព្ទលេខ 1800 280 203*** ហើយសុំនិយាយជាមួយ Equal Opportunity SA។

អ៊ីមែល៖ Equal@sa.gov.au

គេហទំព័រ៖ www.equalopportunity.sa.gov.au

តាមដានពួកយើងនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម

WE'RE EQUAL យើងស្មើគ្នា